មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

**ភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២**

## ម.ស.ម.ក អំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបឲ្យប្រយុទ្ធប្រឆាំងអំពើហិង្សាដែលកើតចេញពីភាពស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា ប្រឆាំងលើស្ត្រី

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម. ស. ម. ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ថ្ងៃនេះចេញផ្សាយសេចក្តីថ្លែងការណ៍មួយអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ឲ្យប្រយុទ្ធប្រឆាំងអំពើហិង្សាដែលកើតចេញពីភាពស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា ប្រឆាំងលើស្ត្រី។ ថ្ងៃទី៨ ខែមីនា ស្អែកនេះ គឺជាទិវាអន្តរជាតិនារី ដែលមនុស្សនៅទូទាំងពិភពលោករួមគ្នាប្រារព្ធទិវាជាប្រវត្តិសាស្ត្រនេះ ដោយបង្ហាញអំពីស្នាដៃ និងការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងវប្បធម៌។ ដើម្បីអបអរសាទរទិវាអន្តរជាតិនារីលើកទី១០១នេះ អង្គការសហប្រជាជាតិ បានកំណត់ប្រធានបទទូទៅមួយថា "ពង្រឹងអំណាចស្ត្រីនៅជនបទ – បញ្ចប់ភាពអត់ឃ្លាន និងភាពក្រីក្រ" ខណៈដែលប្រទេសកម្ពុជាប្រារព្ធទិវានេះក្រោមប្រធានបទ "អ្នកម្តាយដ៏ឆ្នើមរបស់ខ្ញុំ!"។

នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ថា"ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ"។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទជាស្ត្រី ("ស្ត្រីស្រឡាញ់ភេទដូចគ្នា") នៅមិនទាន់ត្រូវបានគេទទួលស្គាល់ ហើយបញ្ហារបស់ពួកគាត់នៅមិនទាន់លើកមកពិភាក្សានៅឡើយទេ បើទោះជាជនរងគ្រោះទាំងនេះបាននិងកំពុងប្រឈមនឹងអំពើហិង្សា ការរើសអើង និងការផាត់ចេញពីសង្គមយ៉ាងធ្ងន់ធ្ងរក៏ដោយ។ ដូច្នេះហើយទើបនៅខណៈដែលស្ត្រី*ទូទៅ* ប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ និងវិសមភាព ស្ត្រីស្រឡាញ់ភេទដូចគ្នា បាននិងកំពុងទទួលរងនូវបញ្ហាប្រឈមផ្ទួនគ្នា។

កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២ គេហទំព័រព័ត៌មាន ("*អ៊ិចស្ត្រា*") ស្តីពីអ្នកស្រឡាញ់ភេទដូចគ្នានៅកាណាដា បានរាយការណ៍នៅក្នុងអត្ថបទរបស់ខ្លួន "របររកស៊ីផ្លូវភេទនៅកម្ពុជា" ថាអ្នកប្តូរភេទជាស្ត្រីត្រូវបានគេបដិសេធឱកាសការងារ បើសូម្បីតែការងារដែលទទួលបានប្រាក់បៀវត្សតិចតួចដូចជាការងារនៅតាមភោជនីយដ្ឋាន និងការងារក្នុងរោងចក្រកាត់ដេរក៏ដោយ ហើយថាអ្នកប្តូរភេទជាស្ត្រីបាននិងកំពុងប្រឈមនឹងការរើសអើងជាច្រើន ពីសំណាក់ក្រុមគ្រួសារ មិត្តភក្តិ និងសង្គម ដែលពួកគាត់មិនអាចរកការងារជាប់លាប់ធ្វើបាន។ សំ សីលា ជាអ្នកប្តូរភេទទៅជាស្ត្រីបានលើកឡើងថា អ្នកប្តូរភេទមានទេពកោសល្យជាច្រើនដែលសង្គមកម្ពុជាមើលរំលង ហើយមិនទទួលស្គាល់នៅឡើយ។ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ កន្លងទៅគេហទំព័រព័ត៌មានកម្ពុជា *ខេមបូឌាន ហេរ៉ល* "តារាសម្តែងប្តូរភេទអំពាវនាវឲ្យបញ្ឈប់អំពើរើសអើង បន្ទាប់ពីទទួលបានពានរង្វាន់តារាសម្តែងភេទទីបីឆ្នើម" បានរាយការណ៍ថា កញ្ញា ប៉ុបពី ដែលជាតារាប្តូរភេទទៅជាស្ត្រី និងជាពិធីការនីកម្មវិធី "ដើមភូមិ ចុងភូមិ" របស់ស្ថានីយ៍ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដែលទើបតែទទួលបានពានរង្វាន់អាណាចក្រតារានាពេលថ្មីៗនេះ បានអំពាវនាវឲ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបបញ្ឈប់អំពើរើសអើងប្រឆាំងនឹងរូបនាង។

**លោក ហែម សុខលី អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានមានប្រសាសន៍ថា៖**

*"ម.ស.ម.ក ទទួលស្គាល់ស្នាដៃរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ប្រសិនបើស្ត្រីគ្រប់ៗរូប មិនថាមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័របែបណាទេ ពួកគាត់គួរនឹងទទួលបានការទទួលស្គាល់ ការគោរព និងសមភាពពេញលេញ។ រាជរដ្ឋាភិបាល ត្រូវធានាសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តដល់ស្ត្រីដែលជាអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈការអនុម័តច្បាប់ប្រឆាំងអំពើហិង្សា ហើយត្រូវបញ្ចូលបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងរបៀបវារៈនៃគោលនយោបាយរបស់ខ្លួន ដើម្បីបញ្ចប់អំពើរើសអើង និងអាកប្បកិរិយាស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា និងអំពើហិង្សា ប្រឆាំងលើស្ត្រីដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។ រាជរដ្ឋាភិបាល ត្រូវធានាផងដែរថា ប្រជាពលរដ្ឋគ្រប់រូបត្រូវរួចផុតពីអំពើហិង្សា និងការរើសអើង ហើយថាប្រជាពលរដ្ឋគ្រប់មានសិទ្ធិដូចៗគ្នា មិនថាពួកគេមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រដូចម្តេចក៏ដោយ"។*

**សម្រាប់ព័ត៌មានបន្ថែមទំនាក់ទំនង លោក ហែម សុខលី តាមរយៈអ៊ីម៉ែល: soklyhem@cchrcambodia.org ទូរស័ព្ទ: ០៩២ ៨០៥ ៨០៨**

**–ចប់–**